



# ព្រះរាជាណាចក្រកម្ពុជា
## ជាតិ សាសនា ព្រះមហាក្សត្រ

# របាយការណ៍លទ្ធផល
## សិក្ខាសាលាពិគ្រោះយោបល់ប្រមូលធាតុចូលស្តីពីការកាន់កាប់អាស្រ័យផលរបស់សហគមន៍
## សម្រាប់វិសោធនកម្មច្បាប់ស្តីពីព្រៃឈើ និងច្បាប់ស្តីពីតំបន់ការពារធម្មជាតិ

សហការរៀបចំដោយ / Co-organized by: NCDD, The NGO Forum on Cambodia

គាំទ្រឧបត្ថម្ភដោយ/ Supported by: MRLG, HEKS EPER, Sverige, Diakonia, UNDP, ClientEarth, Norwegian People's Aid, International Land Coalition, OXFAM

## ១. សេចក្តីផ្តើម

ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ គឺជាយុទ្ធសាស្ត្រដ៏សំខាន់មួយនៅក្នុងការធ្វើឱ្យកាន់តែប្រសើរឡើងនូវការអភិវឌ្ឍនៅថ្នាក់មូលដ្ឋាន និងកាត់បន្ថយភាពក្រីក្រ ដែលត្រូវបានកំណត់នៅក្នុងក្របខណ្ឌយុទ្ធសាស្ត្រស្តីពីកំណែទម្រង់វិមជ្ឈការ និងវិសហមជ្ឈការរបស់រាជរដ្ឋាភិបាល។ រហូតមកដល់ពេលបច្ចុប្បន្ននេះ រាជរដ្ឋាភិបាលបានអនុម័តនូវច្បាប់រៀបចំអង្គការ និងបង្កើតឱ្យមានក្រុមប្រឹក្សានានានៃរដ្ឋបាលថ្នាក់ក្រោមជាតិ ក៏ដូចជា រៀបចំឱ្យមានកម្មវិធីជាតិ១០ឆ្នាំសម្រាប់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ ក្នុងគោលបំណងឱ្យមានរដ្ឋបាលឯកភាពនៅថ្នាក់ក្រោមជាតិ ដែលមានលទ្ធភាពនៅក្នុងការផ្តល់ការអភិវឌ្ឍមូលដ្ឋាន និងធ្វើឱ្យប្រសើរឡើងនូវការគ្រប់គ្រង និងការផ្តល់សេវាសាធារណៈ ដើម្បីឆ្លើយតបទៅនឹងតម្រូវការជាអាទិភាពរបស់ប្រជាពលរដ្ឋនៅមូលដ្ឋាន និងកាត់បន្ថយភាពក្រីក្រ។

ចក្ខុវិស័យរបស់រាជរដ្ឋាភិបាលគឺ ការកសាងរដ្ឋបាលសាធារណៈឱ្យកាន់តែមានប្រសិទ្ធភាព មានប្រសិទ្ធផល និងជំនឿទុកចិត្ត ហើយលើកកម្ពស់ការផ្តល់សេវាសាធារណៈ លើកកម្ពស់មនសិការវិជ្ជាជីវៈរបស់មន្ត្រីរាជការ ព្រមទាំងប្រែក្លាយរដ្ឋបាលសាធារណៈឱ្យទៅជាអ្នកផ្តល់សេវាសាធារណៈដ៏មានប្រសិទ្ធភាព ដើម្បីឆ្លើយតបនឹងតម្រូវការ និងបម្រើប្រជាពលរដ្ឋឱ្យកាន់តែប្រសើរឡើង។

នៅឆ្នាំ២០១៩កន្លងមក រាជរដ្ឋាភិបាលបានសម្រេចធ្វើកំណែទម្រង់រចនាសម្ព័ន្ធរដ្ឋបាលក្រុង ស្រុក ខណ្ឌ ដោយបានធ្វើសមាហរណកម្មការិយាល័យជំនាញនានានៅថ្នាក់ក្រុង ស្រុក ខណ្ឌ មកស្ថិតនៅក្រោមរចនាសម្ព័ន្ធរដ្ឋបាលក្រុង ស្រុក ខណ្ឌ និងបានផ្ទេរមុខងារ និងធនធានពីថ្នាក់ជាតិទៅឱ្យរដ្ឋបាលក្រុង ស្រុក ខណ្ឌ គ្រប់គ្រង និងអនុវត្តតាមរយៈអនុក្រឹត្យលេខ ១៨២ អនុក្រឹត្យលេខ១៨៣ និងអនុក្រឹត្យលេខ១៨៤ ស្តីពីមុខងារ និងរចនាសម្ព័ន្ធរបស់រដ្ឋបាលក្រុង ស្រុក ខណ្ឌ។ ទន្ទឹមនេះ មុខងារ និងធនធាននៃវិស័យធនធានធម្មជាតិ ក៏បានផ្ទេរទៅឱ្យរដ្ឋបាលក្រុង ស្រុក ខណ្ឌគ្រប់គ្រងផងដែរ។

ទន្ទឹមនេះ គណៈកម្មាធិការជាតិសម្រាប់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ (គ.ជ.អ.ប) ដែលមានលេខាធិការដ្ឋានគ.ជ.អ.ប ជាសេនាធិការបាននឹងកំពុងដឹកនាំនិងសម្របសម្រួលក្រុមការងារបច្ចេកទេសអន្តរក្រសួង រួមមានក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ និងក្រសួងបរិស្ថាន រៀបចំវិសោធនកម្ម ច្បាប់ស្តីពីព្រៃឈើ ច្បាប់ស្តីពីជលផល និងច្បាប់ស្តីពីតំបន់ការពារធម្មជាតិ។ ហេតុដូច្នេះ លេខាធិការដ្ឋានគ.ជ.អ.ប ដោយទទួលបានកិច្ចសហការ និងគាំទ្រពីអង្គការ NGO Forum បានរៀបចំសិក្ខាសាលាពិគ្រោះយោបល់នៅថ្នាក់ក្រោមជាតិចំនួន ៣ ដើម្បីប្រមូលធាតុចូលពីរដ្ឋបាលថ្នាក់ក្រោមជាតិ មន្ទីរជំនាញពាក់ព័ន្ធ អង្គការសង្គមស៊ីវិល និងសហគមន៍សម្រាប់ការតាក់តែងសេចក្តីព្រាងវិសោធនកម្មច្បាប់ស្តីពីព្រៃឈើ និងច្បាប់ស្តីពីតំបន់ការពារធម្មជាតិ។ សិក្ខាសាលាទាំងបីតំបន់បានបែងចែកដូចខាងក្រោម ៖

- **សិក្ខាសាលាតំបន់ទី១** ប្រព្រឹត្តិទៅសាលប្រជុំសាលាខេត្តព្រះវិហារ កាលពីទី០៥ ខែឧសភា ឆ្នាំ២០២២ នៅខេត្តព្រះវិហារ ដែលមានសមាសភាពចូលរួមពីរដ្ឋបាលថ្នាក់ក្រោមជាតិរួមមាន ខេត្តព្រះវិហារ ខេត្តបាត់ដំបង ខេត្តសៀមរាប ខេត្តកំពង់ធំ និងឧត្តរមានជ័យ។
- **សិក្ខាសាលាតំបន់ទី២** ប្រព្រឹត្តិទៅសណ្ឋាគារ ហ៊ារ ប៊ុននី ខេត្តក្រចេះ កាលពីទី០៥ ខែឧសភា ឆ្នាំ ២០២២ ដែលមានសមាសភាពចូលរួមពីរដ្ឋបាលថ្នាក់ក្រោមជាតិរួមមាន ខេត្តក្រចេះ ខេត្តមណ្ឌលគីរី ខេត្តរតនគីរី និងខេត្តស្ទឹងត្រែង
- **សិក្ខាសាលាតំបន់ទី៣** ប្រព្រឹត្តិទៅសាលប្រជុំសាលាខេត្តកំពតនៅខេត្តកំពត កាលពីទី១១ ខែឧសភា ឆ្នាំ ២០២២ ដែលមានសមាសភាពចូលរួមពីរដ្ឋបាលថ្នាក់ក្រោមជាតិរួមមាន ខេត្តកំពត ខេត្តព្រះសីហនុ ខេត្តកំពង់ស្ពឺ ខេត្តកោះកុង ខេត្តពោធិ៍សាត់ និងខេត្តកំពង់ឆ្នាំង ។

**២. គោលបំណង**

សិក្ខាសាលាពិគ្រោះយោបល់នេះ បានរៀបចំឡើងក្នុងគោលបំណងសំខាន់ ដូចខាងក្រោម ៖

១. បង្ហាញអំពីវឌ្ឍនភាពនិងសេចក្តីព្រាងច្បាប់ស្តីពីព្រៃឈើ សេចក្តីព្រាងច្បាប់ស្តីពីតំបន់ការពារធម្មជាតិ និងលទ្ធផលនៃការសិក្សាអំពីបទដ្ឋានពាក់ព័ន្ធនឹងការកាន់កាប់អាស្រ័យផលរបស់សហគមន៍ក្នុងតំបន់ព្រៃឈើ រួមទាំងបទដ្ឋា នពាក់ព័ន្ធសហគមន៍តំបន់ការពារធម្មជាតិ ។

២. ផ្តល់ឱកាសឱ្យមានការពិភាក្សាប្រមូលធាតុចូលពីរដ្ឋបាលថ្នាក់ក្រោមជាតិ សង្គមស៊ីវិល និងសហគមន៍មូលដ្ឋានសម្រាប់ដំណើរការវិសោធនកម្មច្បាប់ស្តីពីព្រៃឈើ និងច្បាប់ស្តីពីតំបន់ការពារធម្មជាតិ ។

៣. រៀបចំកិច្ចប្រជុំពិគ្រោះយោបល់ថ្នាក់ជាតិជាមួយអន្តរក្រសួង អង្គការសង្គមស៊ីវិល ដៃគូអភិវឌ្ឍន៍ និងតំណាងសហគមន៍មូលដ្ឋាន ដើម្បីពិភាក្សាលម្អិតអំពីធាតុចូល ដែលទទួលបានពីថ្នាក់ក្រោមជាតិ ។

**៣. សមាសភាពចូលរួម**

សិក្ខាសាលាពិគ្រោះយោបល់ទាំង៣តំបន់នេះមានការចូលរួមពីសមាជិក សមាជិកាប្រមាណជា **៣១១នាក់ ស្រីចំនួន៥៤នាក់** ដែលមានសមាសភាពមកពី៖

**១. តំណាងថ្នាក់ជាតិ**

- **ឯកឧត្តម ខាន់ សុផា អនុរដ្ឋលេខាធិការក្រសួងមហាផ្ទៃ និងជាអនុប្រធានលេខាធិការដ្ឋាន គ.ជ.អ.ប** (តាមអនឡាញ)
- តំណាងក្រសួងមហាផ្ទៃ
- តំណាងក្រសួងបរិស្ថាន
- តំណាងក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ (រដ្ឋបាលព្រៃឈើ និងជលផល)
- តំណាងលេខាធិការដ្ឋាន គ.ជ.អ.ប.

**២. តំណាងរដ្ឋបាលថ្នាក់ក្រោមជាតិ**

| **សិក្ខាសាលាលើកទី១<br>នៅខេត្តព្រះវិហារ** | **សិក្ខាសាលាលើកទី២<br>នៅខេត្តក្រចេះ** | **សិក្ខាសាលាលើកទី៣<br>នៅខេត្តកំពត** |
|---|---|---|
| អភិបាលរងទទួលបន្ទុកការងារគ្រប់គ្រងធនធានធម្មជាតិ<br>- ឯកឧត្តម **លី សារ៉ារិទ្ធ** អភិបាលរងខេត្តព្រះវិហារ<br>- ឯកឧត្តម **ខាន់ តារា** អភិបាលរងខេត្តកំពង់ធំ<br>- ឯកឧត្តម **ច្រាក់ សោភ័ណ** អភិបាលរងខេត្តសៀមរាប<br>- ឯកឧត្តម **ហួន ខ៊ាន់និត** អភិបាលរងខេត្តឧត្តរមានជ័យ | អភិបាលរងទទួលបន្ទុកការងារគ្រប់គ្រងធនធានធម្មជាតិ<br>- ឯកឧត្តម **ម៉ែន លីណាត** អភិបាលរងខេត្តក្រចេះ<br>- ឯកឧត្តម **ជាក់ ម៉េងហ៊ាង** អភិបាលរងខេត្តមណ្ឌលគីរី | អភិបាលរងទទួលបន្ទុកការងារគ្រប់គ្រងធនធានធម្មជាតិ<br>- ឯកឧត្តម **នៃ គង់** អភិបាលរងខេត្តកំពត<br>- ឯកឧត្តម **នៃ ចារី** អភិបាលរងខេត្តកំពង់ឆ្នាំង<br>- ឯកឧត្តម **គង់ វីតាណៈ** អភិបាលរងខេត្តព្រះសីហនុ<br>- ឯកឧត្តម **សុខ តា** អភិបាលរងខេត្តកំពង់ស្ពឺ |
| - អភិបាលក្រុង ស្រុក<br>- ប្រធានមន្ទីររៀបចំដែនដី នគរូបនីយកម្ម សំណង់ និងសុរិយោដី<br>- ប្រធានមន្ទីរបរិស្ថាននិងមន្ត្រីបច្ចេកទេស<br>- នាយកខណ្ឌរដ្ឋបាលព្រៃឈើ | - អភិបាលក្រុង ស្រុក<br>- ប្រធានមន្ទីររៀបចំដែនដី នគរូបនីយកម្ម សំណង់ និងសុរិយោដី<br>- ប្រធានមន្ទីរបរិស្ថាននិងមន្ត្រីបច្ចេកទេស<br>នាយកខណ្ឌរដ្ឋបាលព្រៃឈើ | - អភិបាលក្រុង ស្រុក<br>- ប្រធានមន្ទីររៀបចំដែនដី នគរូបនីយកម្ម សំណង់ និងសុរិយោដី<br>- ប្រធានមន្ទីរបរិស្ថាននិងមន្ត្រីបច្ចេកទេស<br>នាយកខណ្ឌរដ្ឋបាលព្រៃឈើ |

**៣. តំណាងអង្គការ សង្គមស៊ីវិល និងដៃគូនានា៖** សាកលវិទ្យាល័យ, MRLG, RECOFTC, WCS, FAO, HA, CEDT, WMC, HEKS, Birdlife, NTFP-EP, MB, MVI, CEPA, CIYA, CIPO, CIWG និងNGO Forum ។

**៤. តំណាងសហគមន៍៖** សហគមន៍ព្រៃឈើ, សហគមន៍តំបន់ការពារធម្មជាតិ, និងសហគមន៍ជាតិដើមភាគតិច។

## ៤. ដំណើរការសិក្ខាសាលា

សិក្ខាសាលាពិគ្រោះយោបល់នេះត្រូវបានប្រព្រឹត្តទៅតាមពេលវេលា និងកម្មវិធីដែលបានគ្រោងទុក ដែលក្នុងនោះរួមមានសកម្មភាពសំខាន់ៗដូចខាងក្រោម៖

**ក.កិច្ចចាប់ផ្ដើមសិក្ខាសាលា ÷**

ក្នុងពេលចាប់ផ្ដើមសិក្ខាសាលានាពេលព្រឹក អ្នកសម្របសម្រួលបានធ្វើគារវកិច្ច និងស្វាគមន៍ដល់សមាជិកសមាជិកានៃអង្គសិក្ខាសាលា ការគោរពទង់ជាតិនៃព្រះរាជណាចក្រកម្ពុជា ប្រកាសគណៈអធិបតី និងប្រកាសហេតុព្រមទាំងការជម្រាបជូនអង្គសិក្ខាសាលាអំពីគោលបំណងសិក្ខាសាលា ប្រធានបទ និងវិធីសាស្ត្រសំខាន់ៗដែលត្រូវប្រើប្រាស់សម្រាប់ការពិភាក្សាក្នុងអង្គសិក្ខាសាលានេះ។

**ខ.ខ្លឹមសារ និងអត្ថន័យបទបង្ហាញ ÷**

បន្ទាប់ពីកិច្ចចាប់ផ្ដើមអង្គសិក្ខាសាលា សិក្ខាកាមបានទទួលស្ដាប់នូវការធ្វើបទបង្ហាញរបស់វាគ្មិនសំខាន់ៗចំនួន ៦បទបង្ហាញ ដែលរួមមានដូចខាងក្រោម៖

- បទបង្ហាញ «**វឌ្ឍនភាព និងសេចក្ដីព្រាងច្បាប់ស្ដីពី តំបន់ការពារធម្មជាតិ** » ដោយតំណាងក្រសួងបរិស្ថាន ដោយផ្ដោតសំខាន់ទៅលើជំពូកទី៦ ស្ដីពីការចូលរួមនិងសិទ្ធប្រើប្រាស់របស់សហគមន៍មូលដ្ឋាននៃសេចក្ដីព្រាងច្បាប់ថ្មីស្ដីពីតំបន់ការពារធម្មជាតិដែលបានចែងអំពីសិទ្ធរបស់សហគមន៍មូលដ្ឋានក្នុងការចូលរួម ផ្ដល់នឹងទទួលយកព័តមានទាក់ទងនឹងការគ្រប់គ្រង ការអភិរក្សនិងអភិវឌ្ឍក្នុងតំបន់ការពារធម្មជាតិ និងសិទ្ធប្រើប្រាស់ធនធានធម្មជាតិលក្ខណៈប្រពៃណី ទំនៀមទម្លាប់តាមតម្រូវការរបស់សហគមន៍ជាលក្ខណៈគ្រួសារនៅក្នុងតំបន់ប្រើប្រាស់ដោយចីរភាពនិងតំបន់អភិរក្ស តាមគោលការណ៍ណែនាំដែលបានកំណត់។ ជាមួយគ្នានេះ ក៏បានចែងអំពីសិទ្ធិ តួនាទីភារកិច្ចក្រសួងបរិស្ថាន និងរដ្ឋបាលថ្នាក់ក្រោមជាតិក្នុងការផ្ដល់និងលប់កិច្ចសន្យាសហគមន៍តំបន់ការពារធម្មជាតិ សម្របសម្រួល គាំទ្រ ផ្ដល់គោលការណ៍អនុញ្ញាត និងទទួលស្គាល់ដល់ការបង្កើតសហគមន៍តំបន់ការពារធម្មជាតិ ។
- បទបង្ហាញ «**វិសោធនកម្មច្បាប់ស្ដីពីព្រៃឈើ**» ដោយលលោក **ឡុង រត្តនៈកុមារ** អនុប្រធាននាយកដ្ឋានក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ។ បទង្ហាញបានបង្ហាញអំពីលិខិតបទដ្ឋានគតិយុត្តិពាក់ព័ន្ធនឹងការគ្រប់គ្រងព្រៃឈើ វាក្យស័ព្ទដែលប្រើនៅក្នុងសេចក្ដីព្រាងច្បាប់ថ្មី និងលើកយកតែផ្នែកទី៦ អំពីព្រៃ

សហគមន៍នៃជំពូកទី៥ការគ្រប់គ្រងព្រៃផ្តល់ផលមកអធិប្បាយក្នុងអង្គសិក្ខាសាលា។ ក្នុងផ្នែកទី៦នេះ បានបរិយាយអំពីព្រៃហគមន៍ដែលជាផ្នែកមួយនៃព្រៃផ្តល់ផលត្រូវបានផ្តល់ដោយក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ដើម្បីគ្រប់គ្រងក្នុងលក្ខណៈសេដ្ឋកិច្ច អភិវឌ្ឍន៍ និងប្រើប្រាស់ធនធានព្រៃឈើដោយនិរន្តភាពតាមរយៈការបង្កើតសហគមន៍ព្រៃឈើ ស្របតាមគោលការណែនាំអំពីសហគមន៍ព្រៃឈើ។ ការកំណត់អំពីលិខិតបទដ្ឋាននៃបង្កើត គ្រប់គ្រង និងប្រើប្រាស់ព្រៃសហគមន៍ និងសិទ្ធិប្រើប្រាស់ជាប្រពៃណីលើផល អនុផលព្រៃឈើដោយសហគមន៍មូលដ្ឋាន ព្រមទាំងចែងអំពីតួនាទី ភារកិច្ចរបស់ក្រសួង ស្ថាប័នពាក់ព័ន្ធនិងរដ្ឋបាលថ្នាក់ក្រោមជាតិក្នុងការគ្រប់គ្រង សម្របសម្រួល គាំទ្រ និងតាមដានលើការអនុវត្តផែនការគ្រប់គ្រង និងអភិវឌ្ឍន៍ព្រៃឈើសហគមន៍ និងប្រភពថវិកាសម្រាប់ទ្រទ្រង់ដំណើរការរៀបចំនិងអនុវត្តផែនការគ្រប់គ្រង និងអភិវឌ្ឍន៍ព្រៃឈើសហគមន៍ដែលបានមកពីថវិការដ្ឋ ថវិកាពីមូលនិធិអភិវឌ្ឍន៍ព្រៃឈើជាតិ និងថវិកាពីដៃគូអភិវឌ្ឍន៍ វិស័យឯកជន និងសប្បុរសជន។

- បទបង្ហាញ **«ការវិភាគលើក្របខ័ណ្ឌច្បាប់ បទពិសោធន៍ និងអនុសាសន៍ណែនាំនៃសហគមន៍តំបន់ការពារធម្មជាតិនៅកម្ពុជា»** តំណាង **អង្គការ** Client Earth បានបង្ហាញអំពីលទ្ធផលនៃការសិក្សា ស្វែងយល់ និងរកឃើញនូវបញ្ហាខ្វះខាត បទពិសោធន៍ និងអនុសាសមួយចំនួនដែលពាក់ព័ន្ធនឹងសហគមន៍តំបន់ការពារធម្មជាតិដែលមានដូចជា:

១. ការកាន់កាប់ដីធ្លី: គឺបណ្តាលមកពីអសន្តិសុខនៃការកាន់កាប់ដីធ្លី ដែលសហគមន៍មានសិទ្ធិតែមួយផ្នែកប៉ុណ្ណោះ (សិទ្ធិចេញ-ចូល សិទ្ធិប្រើប្រាស់ សិទ្ធិដកហូត និងសិទ្ធិគ្រប់គ្រង ប៉ុន្តែមិនមានសិទ្ធិផ្តាច់មុខនោះទេ)។ ជាអនុសាសៈ គួរប្រែក្លាយជាផ្លូវការនូវសិទ្ធិកាន់កាប់ដីធ្លី ជានាសិទ្ធិកាន់កាប់ដីធ្លីឱ្យកាន់តែសមស្រប និងបន្ថែមរយៈពេលកាន់កាប់ដីធ្លីយ៉ាងតិច៣០ឆ្នាំ។

២. ការទទួលបានទីផ្សារៈ ខ្វះភាពច្បាស់លាស់នៃតម្រូវការបទប្បញ្ញត្តិសម្រាប់សកម្មភាពសេដ្ឋកិច្ច (ដូចជាលិខិតអនុញ្ញាត អាជ្ញាធរទទួលបន្ទុក និងបទប្បញ្ញត្តិពាក់ព័ន្ធ)។ អនុសាសន៍ៈ គួរបញ្ជាក់និងអភិវឌ្ឍក្របខណ្ឌច្បាប់ស្តីពីការទទួលបានទីផ្សារនៅក្នុងសហគមន៍តំបន់ការពារធម្មជាតិ និងពង្រឹងភាពជាដៃគូររវាងសហគមន៍តំបន់ការពារធម្មជាតិ និងវិស័យឯកជន និងគាំទ្រការពង្រឹងសមត្ថភាពរបស់សហគមន៍។

៣. ការបង្កើតសហគមន៍តំបន់ការពារធម្មជាតិៈ មានភាពស្មុគស្មាញផ្នែករដ្ឋបាលនៃការបង្កើតសហគមន៍តំបន់ការពារធម្មជាតិ។ អនុសាសន៍ៈ សម្រួលដំណាក់កាលនៃការបង្កើតសហគមន៍តំបន់ការពារធម្មជាតិ និងធានានូវការចូលរួមរបស់សហគមន៍មូលដ្ឋាននៅក្នុងការកំណត់ផែនទីនិងបែងចែកតំបន់គ្រប់គ្រងនៃតំបន់ការពារធម្មជាតិ និងសហគមន៍តំបន់ការពារធម្មជាតិ។

៤. អភិបាលកិច្ចផ្ទៃក្នុងសហគមន៍និងការតំណាង និងការចូលរួមពីសហគមន៍ៈ ខ្វះការណែនាំនិងការធ្វើសេចក្តីសម្រេចចិត្តពីក្រុមងាយរងគ្រោះ។ អនុសាសន៍ៈ ផ្តល់យន្តការគណនេយ្យភាពនិងតម្លាភាព និងជ្រើសរើសក្រុងបុគ្គលងាយរងគ្រោះ និងពង្រឹងការការពារដើម្បីជំរុញការចូលរួម។

៥. ការគ្រប់គ្រងសហគមន៍តំបន់ការពារធម្មជាតិ និងការបែងចែកផលប្រយោជន៍៖ ផែនការគ្រប់គ្រងសហគមន៍មានភាពស្មុគស្មាញសម្រាប់អនុវត្ត និងកង្វះខាតភាពច្បាស់លាស់លើការបែងចែកផលប្រយោជន៍។ អនុសាសន៍៖ សម្របសម្រួលលក្ខខណ្ឌផែនការគ្រប់គ្រង ពង្រីកសិទ្ធិគ្រប់គ្រងរបស់សហគមន៍ និងផ្តល់ការណែនាំបន្ថែមសម្រាប់បែងចែកផលប្រយោជន៍។

៦. ដំណោះស្រាយវិវាទ៖ សហគមន៍តំបន់ការពារធម្មជាតិភាគច្រើនស្ថិតនៅក្នុងស្ថានការណ៍មិនអំណោយផលនៅពេលដែលមានវិវាទដីធ្លី។ អនុសាសន៍៖ បង្កើតគោលការណ៍ណែនាំច្បាស់លាស់ និងបទដ្ឋានអនុវត្តសម្រាប់ការដោះស្រាយជម្លោះ(អនុវត្តបែបប្រពៃណី ទំនៀមទម្លាប់)។

៧. ការអនុវត្តច្បាប់៖ ការអនុវត្តច្បាប់មិនបានតឹងរឹង និងខ្វះការពិន័យឱ្យបានសមរម្យ។ អនុសាសន៍៖ ផ្តល់អំណាចបន្ថែមឱ្យទៅសហគមន៍ក្នុងអនុវត្តច្បាប់ និងធានាឱ្យនូវធនធាននិងសមត្ថភាពសម្រាប់ការចុះល្បាតនិងអនុវត្តច្បាប់។

៨. ការគាំទ្រពីខាងក្រៅ៖ តួនាទីដ៏សំខាន់របស់អង្គការក្រៅរដ្ឋាភិបាលក្នុងការផ្តល់ជំនួយបច្ចេកទេស និងហិរញ្ញវត្ថុដល់សហគមន៍តំបន់ការពារ។

៩. អនុសាសន៍៖ ភាពចាំបាច់នៃកិច្ចសហការច្រើនជាងមុនរវាងសហគមន៍តំបន់ការពារ និងវិស័យឯកជន។ ភាពចាំបាច់ក្នុងការផ្តល់ថវិកាគ្រប់គ្រាន់ និងកសាងសមត្ថភាពពីរដ្ឋាភិបាលដល់សហគមន៍តំបន់ការពារធម្មជាតិ។

១០. បរិយាយអំពីមេរៀន និងបទពិសោធន៍ល្អៗដែលទទួលបានពីប្រទេសដទៃ ដូចជានៅតំបន់អាហ្វ្រិកខាងលិច (ប្រទេសហ្គាបុង និងសាធារណរដ្ឋកុងហ្គោ) និងតំបន់អាហ្វ្រិកកណ្តាល (ប្រទេសលីបេរីយ៉ា ប្រទេសហ្គាណា និងប្រទេសកូតឌីវ័រ) ជាដើម បទពិសោធន៍ពីការអនុវត្តល្អៗ រួមមាន៖ កំណែទម្រង់ផ្នែកច្បាប់ ប្រទេសលីបេរីយ៉ា ក្របខណ្ឌច្បាប់ស្តីពីព្រៃឈើមានការទទួលស្គាល់សិទ្ធិកាន់កាប់ដីបែបប្រពៃណីនិងសារៈសំខាន់សហគមន៍ក្នុងការគ្រប់គ្រងធនធានព្រៃឈើ។ ចំពោះសាធារណរដ្ឋកុងហ្គោបានអនុវត្តជោគជ័យនូវក្រមស្តីពីព្រៃឈើ(២០២១) ដែលមានការចូលរួមយ៉ាងសកម្មនិងប្រសិទ្ធភាពពីអង្គការសង្គមស៊ីវិលក្នុងជំហាននីមួយៗនៃការអនុវត្តនីតិវិធី។

១១. កាអនុវត្តល្អៗអំពីការទទួលបានទីផ្សារ ប្រទេសលីបរីយ៉ា អង្គការ ClientEarth និងដៃគូក្នុងប្រទេសបានបង្កើតកិច្ចសន្យាគំរូសម្រាប់ពាណិជ្ជកម្មទ្រង់ទ្រាយមធ្យម(MS-CUC) ដើម្បីបង្កើតបទដ្ឋាននៃកិច្ចព្រមព្រៀងរវាងសហគមន៍និងក្រុមហ៊ុនឈើដែលជាភាគីទីបី។

- បទបង្ហាញស្តីពី «**ការពង្រឹងការចែករំលែកផលប្រយោជន៍ និងឱកាសផ្នែកសេដ្ឋកិច្ចដល់សហគមន៍តំបន់ការពារធម្មជាតិនៅកម្ពុជា**» លោក **សយ ហ្សីឌី** អ្នកសម្របសម្រួលបណ្តាញអភិបាលកិច្ចព្រៃឈើ។ បទបង្ហាញបានបង្ហាញអំពីមាតិកាចំនួន៣ រួមមាន សាវតា ខ្លឹមសារគន្លឹះនិងអនុសាសន៍ និងសេចក្តីសន្និដ្ឋាន។ ក្នុងសាវតាបានបញ្ជាក់អំពី ការពឹងអាស្រ័យធនធានធម្មជាតិរបស់គ្រួសារនៅជនបទ និងសហគមន៍ទទួលបានផលប្រយោជន៍តិចតួចពីការវិនិយោគនិងការការពារធនធានម្មជាតិ។ ចំពោះខ្លឹមសារគ

ន្លឹះៗបានគូសបញ្ជាក់អំពីសិទ្ធិសហគមន៍តំបន់ការពារធម្មជាតិក្នុងការប្រមូលផល ការកែច្នៃ ដឹកជញ្ជូន និងលក់អនុផលព្រៃឈើ ការផ្សព្វផ្សាយគម្រោងទេសចរណ៍ធម្មជាតិតាមសហគមន៍តំបន់ការពារធម្មជាតិរួមទាំងក្នុងតំបន់អភិរក្សដែលបានជ្រើសរើស គណៈកម្មាធិការ CPA គួរត្រូវបានអនុញ្ញាតឱ្យមានសិទ្ធិស្របច្បាប់ក្នុងការចុះហត្ថលេខាលើកិច្ចព្រមព្រៀងជាមួយក្រុមហ៊ុនឯកជន សម្រាប់សកម្មភាពដែលបានកំណត់នៅក្នុងផែនការគ្រប់គ្រងនិងអនុវត្ត និងសហគមន៍តំបន់ការពារធម្មជាតិគួរតែទទួលបានអត្ថប្រយោជន៍ពីសិទ្ធិកាបូនព្រៃឈើតំបន់ការពារធម្មជាតិរបស់ពួកគាត់ តាមរយៈយន្តចែករំលែកអត្ថប្រយោជន៍ប្រកបដោយតម្លាភាព។ ការលើកឡើងនូវអនុសាសន៍សំខាន់ៗដែលពាក់ព័ន្ធនឹងសិទ្ធិប្រើប្រាស់ដីធ្លីរបស់សហគមន៍ ការប្រមូលយកប្រយោជន៍ពីអនុផល និងការអនុវត្តគោលការណ៍ ការពង្រីកវិសាលភាពនៃចម្ការឈើអន្ដោគ្រាម សកម្មភាពស្ដារព្រៃឈើឡើងវិញ និងគម្រោងREDD+ គួរត្រូវបានគិតគូរពិចារណាក្នុងការរៀបចំវិសោធន៍កម្មច្បាប់នេះ។

- បទបង្ហាញស្តីពី **«អនុក្រឹត្យស្តីពីការបង្កើតសហគមន៍ព្រៃឈើ»** លោកសាស្ត្រាចារ្យ **វន មុនិន្ទ** ទីប្រឹក្សាឯករាជ្យ បានបង្ហាញពីមាតិកាសំខាន់ៗចំនួន៧ រួមមានៈ
  - ១. សាវតានៃច្បាប់
  - ២. ទិដ្ឋភាពទូទៅនៃច្បាប់ព្រៃឈើ
  - ៣. អនុក្រឹត្យស្តីពីការបង្កើត/គ្រប់គ្រងសហគមន៍ព្រៃឈើ
  - ៤. ប្រកាសស្តីពីគោលការណ៍ណែនាំអំពីសហគមន៍ព្រៃឈើ
  - ៥. អនុសាសន៍សម្រាប់ការកែសម្រួលច្បាប់ស្តីពីព្រៃឈើឆ្នាំ២០០២
  - ៦. ការវិភាគនិងកែសម្រួលលើពាក្យពេចន៍នៅក្នុងបទបញ្ញាផ្ទៃក្នុងរបស់គណៈកម្មការគ្រប់គ្រង សហគមន៍ព្រៃឈើ លក្ខន្តិកៈសហគមន៍ព្រៃឈើ កិច្ចព្រមព្រៀងព្រៃសហគមន៍ ផែនការគ្រប់គ្រងព្រៃសហគមន៍
  - ៧. សន្និដ្ឋាន និងអនុសាសន៍

បន្ទាប់ពីបទបង្ហាញ អង្គសិក្ខាសាលាបានបែងចែកក្រុមពិភាក្សាអំពីបទពិសោធន៍របស់រដ្ឋបាលថ្នាក់ក្រោមជាតិលើការអភិរក្សធនធានធម្មជាតិ និងបទង្ហាញលទ្ធផលក្រុមពិភាក្សា។

## ៥. លទ្ធផលនៃសិក្ខាសាលា

សិក្ខាសាលារយៈពេល០១ថ្ងៃនេះ អ្នកចូលរួមទទួលបាននូវចំណេះដឹង និងព័ត៌មានសំខាន់ៗដែលពាក់ព័ន្ធនឹងបទដ្ឋានគតិយុត្ត គោលនយោបាយពាក់ព័ន្ធនឹងការអភិរក្សធនធានធម្មជាតិ ការអាស្រ័យផលរបស់សហគមន៍មូលដ្ឋានក្នុងតំបន់ព្រៃឈើ និងសេចក្តីព្រាងច្បាប់ថ្មីស្តីពីព្រៃឈើ និងច្បាប់ស្តីពីតំបន់ការពារធម្មជាតិ ព្រមទាំងបានផ្តល់ជាគុចូល និងអនុសាសន៍សំខាន់ៗជាច្រើន។ ជាពិសេស នៅក្នុងក្រុមពិភាក្សាទាំង៤ ដោយទទួលបានលទ្ធផលជាគន្លឹះ ទៅតាមសំណួរពិភាក្សាដូចខាងក្រោម ៖

**សំណួររួមសម្រាប់ក្រុមពិភាក្សាទាំង០៤៖**

១. តើមានអ្វីបន្ថែមទៀតទេ ក្រៅពីបញ្ហាប្រឈម និងអនុសាសន៍ដែលបង្ហាញដោយវាគ្មិន?

២. តើអាជ្ញាធរថ្នាក់ក្រោមជាតិគួរចូលរួមចំណែកបន្ថែមទៀត(តួនាទី និងការទទួលខុសត្រូវ) យ៉ាងណានៅក្នុងច្បាប់ថ្មី?

៣. តើមានបទពិសោធន៍ល្អអ្វីខ្លះ ដែលចង់ស្នើដាក់បញ្ចូលក្នុងច្បាប់ថ្មីនេះ?

**<u>លទ្ធផលនៃកិច្ចពិភាក្សា</u>**

| ល.រ | មតិយោបល់ និងសំណើរ សំណូមពរ |
|---|---|
| **១. បញ្ហាប្រឈមក្នុងការអនុវត្តច្បាប់ស្តីពីព្រៃឈើ និងច្បាប់ស្តីពីតំបន់ការពារធម្មជាតិ**<br>ក្នុងការអនុវត្តច្បាប់ទាំង២នេះ អ្នកចូលរួមបានជួបប្រទះនូវបញ្ហាប្រឈមមួយចំនួនដូចខាងក្រោម:<br>✓ ពុំទាន់មានបែងចែកតំបន់ស្នូល និងតំនប់ការពារឱ្យបានច្បាស់លាស់នាំឱ្យមានទំនាស់។<br>✓ ប្រជាពលរដ្ឋទូទៅពុំមានសិទ្ធិគ្រប់គ្រាន់ក្នុងការការពារ និងអភិរក្ស។<br>✓ រាល់បទល្មើសត្រូវដោះស្រាយនៅកម្រិតអាជ្ញាធរ និងជំនាញ។<br>✓ ការរុករករ៉ែមិនទាន់មានការពិគ្រោះយោបល់ជាមួយសហគមន៍មូលដ្ឋាន (គ្រួសក្រហម ថ្មសំណង់ ថ្មម៉ាប) ព្រៃសហគមន៍ដែលមានប្រកាសហើយគួរគប្បីរក្សាទុកជាប្រយោជន៍សហគមន៍ ។<br>✓ មិនមានការលើកទឹកចិត្តដល់សហគមន៍មូលដ្ឋាន រួមទាំងការជួសជុលផ្នែករងផលប៉ះពាល់ដល់សហគមន៍ ។<br>✓ គណៈកម្មការ ប្រជាពលរដ្ឋចូលរួមការពារធនធានធម្មជាតិសកម្ម បែរជាទទួលរងពាក្យបណ្តឹងទៅតុលាការទៅវិញ ។<br>✓ វត្ថុតាង (ឈើ) ពេលរិបអូសមិនត្រូវបានផ្តល់សហគមន៍។<br>✓ ក្រសួងរ៉ែនិងថាមពល មិនបានពិគ្រោះយោបល់ជាមួយក្រសួងពាក់ព័ន្ធមុននឹងចេញអាជ្ញាប័ណ្ណណាមួយ។<br>✓ មិនបានផ្តល់សិទ្ធិពេញលេញនិងច្បាស់លាស់។<br>✓ ចំនួនប្រជាជនច្រើន ទំហំដីតូច។ | |
| ២. មតិយោបល់ពាក់ព័ន្ធនឹងសេចក្តីព្រាងច្បាប់ស្តីពីព្រៃឈើ<br>✓ **មាត្រា២៤** កែសម្រួលទៅជា៖ **ស្របតាមអនុក្រឹត្យស្តីពីការគ្រប់គ្រងសហគមន៍ព្រៃឈើ និងប្រកាស គោលការណ៍ណែនាំ** គោលការណ៍ណែនាំអំពីសហគមន៍ព្រៃឈើ។<br>✓ **មាត្រា៥៥** ស្នើដកពាក្យថា ផលប៉ះពាល់ មកប្រើពាក្យថា ពាក់ព័ន្ធជាមួយជីវភាពរស់នៅរបស់សហគមន៍មូលដ្ឋាន។ និងស្នើសុំឱ្យលុបចោលពាក្យ **ធ្ងន់ធ្ងរ** ចេញ។ ស្នើសុំអនុញ្ញាតឱ្យ **សហគមន៍មូលដ្ឋានមានសិទ្ធចូលរួមពិគ្រោះយោបល់ជាសាធារណៈ រាល់ការសម្រេចរបស់រដ្ឋាភិបាលដែលពាក់ព័ន្ធនឹងការគ្រប់គ្រង ការប្រើប្រាស់ និងចាត់ចែងព្រៃសហគមន៍។** | |

- ✓ **មាត្រា៥៦.** បន្ថែមកថាខណ្ឌ៖ **បង្កើតក្រុមវាយតម្លៃហេតុប៉ះពាល់និរន្តភាពព្រៃឈើ និងបង្កើតក្រុមការងារនិងតួនាទីអ្នកវាយតម្លៃហេតុប៉ះពាល់និរន្តភាពព្រៃឈើ។**
- ✓ **មាត្រា៥៦៖** ស្នើសុំកែសម្រួលចំនុចទី២ទៅជា ការប្រើប្រាស់ឈើ **និងអនុផលព្រៃឈើ**មកសង់លំនៅឋានក្រោលសត្វ របង និងសម្រាប់ធ្វើឧបករណ៍កសិកម្ម។
- ✓ **មាត្រា៥៧** ស្នើសុំសរសេរដូចមាត្រា២៤នៃច្បាប់ស្តីពីតំបន់ការពារធម្មជាតិថ្មី ។
- ✓ **មាត្រា៥៨.** កថាខណ្ឌ២ស្នើកែសម្រួលទៅជា៖ អង្គភាពជំនាញទទួលបន្ទុកវិស័យព្រៃពេឈើ និង**រដ្ឋបាលថ្នាក់ក្រោមជាតិមានសមត្ថកិច្ច** មានសិទ្ធិចុះកិច្ចព្រមព្រៀងជាមួយសហគមន៍ព្រៃឈើ ដែលមានប្រកាសទទួលស្គាល់ដោយក្រសួងកសិកម្មរុក្ខាប្រមាញ់និងនេសាទ។
- ✓ **មាត្រា៥៨.** ស្នើសុំរយៈពេលចុះកិច្ចព្រៀងសហគមន៍ព្រៃឈើនឹងរដ្ឋមាន**រយៈពេលមិនលើសពី៥០ឆ្នាំ** (ចំណុចនេះសហគមន៍ព្រៃឈើស្នើសុំចុះកិច្ចព្រមព្រៀងសហគមន៍ព្រៃឈើមានរយៈពេល៥០ឆ្នាំចុះម្តងស្មើនឹងក្រុមរដ្ឋប្បវេណី) ពីព្រោះពិបាកចុះកិច្ចព្រមព្រៀងជាមួយដៃគូឯកជននៅក្នុងការអភិវឌ្ឍសហគមន៍ព្រៃឈើ។
- ✓ **មាត្រា៥៩.** ស្នើកែសម្រួលទៅជា អង្គភាពជំនាញទទួលបន្ទុកវិស័យព្រៃឈើ និង**រដ្ឋបាលថ្នាក់ក្រោមជាតិមានសមត្ថកិច្ច** ជាតំណាងនីតិបុគ្គលរបស់រដ្ឋ ត្រូវស្នើសុំចុះបញ្ជីដីព្រៃសហគមន៍ ដែលទទួលស្គាល់ដោយក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ជាដីសាធារណៈរបស់រដ្ឋស្របតាមនីតិវិធីច្បាប់ និងលិខិតបទដ្ឋានគតិយុត្តពាក់ព័ន្ធ។
- ✓ **មាត្រា៦០៖** ស្នើសុំបន្ថែមពាក្យ អង្គភាពជំនាញទទួលបន្ទុកវិស័យព្រៃឈើ**ថ្នាក់ក្រោមជាតិ** នៅកថាខណ្ឌទី១ ទី២ និងទី៣ និងស្នើសុំកែសម្រួល គណៈកម្មការសហគមន៍ព្រៃឈើ ទៅជា **គណៈកម្មការគ្រប់គ្រងសហគមន៍ព្រៃឈើ** នៅកថាខណ្ឌទី៤។
- ✓ **មាត្រា៦១៖** បន្ថែម **ការចិញ្ចឹមសត្វព្រៃ សួនសត្វធម្មជាតិក្នុងព្រៃសហគមន៍** នៅក្នុងកថាខណ្ឌទី១។
- ✓ **មាត្រា៦៣.** ស្នើកែសម្រួលទៅជាៈ រាជរដ្ឋាភិបាល និង/ឬក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ និង/ឬរដ្ឋបាលថ្នាក់ក្រោមជាតិ អាចផ្តល់ជូនបុគ្គល និងសហគមន៍ព្រៃឈើ ដែលអនុវត្តការគ្រប់គ្រង **ការពារ ថែរក្សា ប្រើប្រាស់ និងអភិវឌ្ឍន៍** ឬដាំដើមឈើដែលសម្រេចបាននូវបរិមាណ និងគុណភាពនូវការលើកទឹកចិត្តមានជាអាទិ៍។
- ✓ ស្នើសុំផ្តល់សិទ្ធិដល់សហគមន៍ក្នុងការសម្រេចចិត្តលើការអភិវឌ្ឍ ជីវភាពរស់នៅរបស់សហគមន៍ (ដោយបន្ថែមនៅក្នុងមាត្រា០៦) នៃសេចក្តីព្រៀងច្បាប់ស្តីពី ព្រៃឈើ ដូចជា ដៃគូអភិវឌ្ឍន៍មានសិទ្ធិទទួលបានផលប្រយោជន៍នៅក្នុងកិច្ចព្រមព្រៀងអភិវឌ្ឍន៍ជាមួយសហគមន៍។
- ✓ ស្នើសុំបង្កើនថវិកាជាតិ (មូលនិធិឃុំ) ក្នុងការការពារធនធានធម្មជាតិ / ព្រៃសហគមន៍ និងអភិរក្សការពារធនធានធម្មជាតិ(ថវិកា សំភារៈសម្រាប់សមត្ថភាពជួយដល់ជនងាយរងគ្រោះ កុមារ និងស្ត្រី)។
- ✓ ស្នើធ្វើបច្ចុប្បន្នភាពគម្របព្រៃឈើក្នុងរយៈពេលពី៥-១០ឆ្នាំម្តង និងចុះបញ្ជីកា។

- ✓ គួររៀបចំឱ្យមានមាត្រាអំពីការធ្វើ**ពាណិជ្ជកម្មអនុផលព្រៃឈើ៖** គួរពង្រីកទីផ្សារឱ្យបានទូលំទូលាយ និងសម្រួលដល់ជីវភាពសហគមន៍ និងយន្តការបែងចែកផលប្រយោជន៍ឱ្យបានច្បាស់លាស់។
- ✓ ស្នើសុំការផ្សព្វផ្សាយដល់សហគមន៍ បើមានគម្រោងឬក្រុមហ៊ុនវិនិយោគនៅក្នុងដីសហគមន៍ ត្រូវមានការពិភាក្សានិងការសម្រេចចិត្តពីសហគមន៍ផ្ទាល់តាមគោលការណ៍អេហ្វពិក (FPIC)។
- ✓ រាល់គម្រោងអភិវឌ្ឍត្រូវឲ្យប្រជាពលរដ្ឋមូលដ្ឋានអ្នកពាក់ព័ន្ធចូលរួមពិគ្រោះយោបល់ពេញលេញ ពោលគឺចូលរួមសម្រេចចិត្តយល់ព្រម។
- ✓ ផ្តល់សិទ្ធិ និងគាំទ្រការបង្កើតបណ្តាញសហគមន៍ព្រៃឈើថ្នាក់ខេត្តរហូតដល់ថ្នាក់ជាតិ ដោយរួមទាំងដំណើរការចុះបញ្ជីជានីតិបុគ្គល បច្ចេកទេស និងថវិកា។
- ✓ ផ្តល់សិទ្ធិឱ្យសហគមន៍ព្រៃឈើ ចាប់ឬឃាត់ខ្លួនជនល្មើសនឹងវត្ថុតាងយកមករក្សាទុកនៅសហគមន៍បណ្តោះអាសន្ន នឹងចូលរួមកសាងសុំណុំរឿងជាមួយមន្ត្រីនគបាលយុត្តិធម៌ និងតាមដានដំណើរការក្តីព្រហ្មទណ្ឌ ។
- ✓ ផ្តល់សិទ្ធិដល់សហគមន៍ក្នុងការបង្ក្រាបបទល្មើសជាក់ស្តែង ជៀសជាងត្រឹមតែសិទ្ធិឃាត់ខ្លួនជនល្មើស និងវត្ថុតាង។
- ✓ ការអភិវឌ្ឍដែលប៉ះពាល់ដល់ដែនសហគមន៍ព្រៃឈើ ត្រូវមានសំណងជាប្រាក់ស្របតាមការព្រមព្រៀងនៃកិច្ចពិគ្រោះយោបល់ជាមួយសមាជិក និងគណៈកម្មការសហគមន៍ព្រៃឈើ និងអាជ្ញាធរមូលដ្ឋាន។
- ✓ ស្នើសុំប្រើពាក្យ ជនណាក៏ដោយឱ្យតែប្រព្រឹត្តិបទល្មើសព្រៃឈើ ត្រូវទទួលទោស រួមទាំងអ្នករួមគំនិត ញុះញង់។
- ✓ ផ្តល់សិទ្ធិឱ្យរដ្ឋបាលខេត្តចេញវិធានការការពារក្នុងអំឡុងពេលដំណើរការចុះបញ្ជីសហគមន៍ព្រៃឈើ។
- ✓ ប្តូរពាក្យ គណៈកម្មការ ទៅជា គណៈកម្មាធិការ ដើម្បីការពារព្រៃបម្រុងទុកអចិន្ត្រៃយ៍។
- ✓ ផ្តល់ប័ណ្ណកម្មសិទ្ធិដីព្រៃសហគមន៍ ដល់សហគមន៍ក្នុងការគ្រប់គ្រង និងអាស្រ័យផល
- ✓ ស្នើសុំបន្ថែមពាក្យ សហគមន៍មូលដ្ឋាន និង**ជនជាតិដើមភាគតិច**

## ៣. មតិយោបល់ពាក់ព័ន្ធនឹងសេចក្តីព្រាងច្បាប់ស្តីពីតំបន់ការពារធម្មជាតិ

- ✓ **មាត្រា២០៖** ស្នើសុំបន្ថែមពាក្យ សហគមន៍មូលដ្ឋាន និង**ជនជាតិដើមភាគតិច** ។
- ✓ **មាត្រា២៣៖** ស្នើសុំប្តូរពាក្យពីចំការពនេចរទៅជា **ចំការវិលជុំ** (ការអនុវត្តន៍ចំការវិលជុំដោយជនជាតិដើមភាគតិចតាមលក្ខណៈប្រពៃណីតែមិនអាចកាត់ខ្ទាល ឈូសឆាយនិងដុតដើម្បីធ្វើចំការ)។
- ✓ **មាត្រា២៤៖** ស្នើសុំវិធានការបង្កើតសហគមន៍តំបន់ការពារធម្មជាតិ ត្រូវកំណត់ត្រឹមត្រូវសេចក្តីប្រកាសរបស់ក្រសួងបរិស្ថាន ហើយមិនបាច់ដល់អនុក្រឹត្យទេ។
- ✓ **មាត្រា២៥** ស្នើសុំប្រើប្រាស់ពាក្យពេចន៍ និងខ្លឹមសារ ដូចមានចែងក្នុងមាត្រា៥៨ថ្មីនៃច្បាប់ស្តីពីព្រៃឈើ។
- ✓ **មាត្រា២៥៖** ស្នើបន្ថែមពាក្យបញ្ជាំ **ឬហ៊ីប៉ូតែត** ក្នុងកថាខណ្ឌទី១។

- ✓ ស្នើសុំឱ្យមានការចុះបញ្ជីដីសហគមន៍ នៅក្រសួងដែនដី នគរូបនីយ៍កម្ម និងសំណង់ ដើម្បីឱ្យសហគមន៍តំបន់ការពារធម្មជាតិមានសិទ្ធិកាន់កាប់ដីធ្លីរឹងមាំថែមទៀត និងត្រូវបានទទួលស្គាល់ជានីតិបុគ្គលស្របច្បាប់ ព្រមទាំងមានសិទ្ធិកំណត់ការចេញចូលលើដីធ្លីក្នុងតំបន់គ្រប់គ្រងក្នុងសហគមន៍តំបន់ការពារធម្មជាតិ ។
- ✓ ច្បាប់ថ្មីគួរចែងពីសិទ្ធិសហគមន៍តំបន់ការពារធម្មជាតិឱ្យបានច្បាស់លាស់ក្នុងការប្រើប្រាស់ដីក្នុងសហគមន៍តំបន់ការពារធម្មជាតិ។ ឧទាហរណ៍ សិទ្ធិប្រើប្រាស់(Usage Right) ដែលអាចបែងចែងផែនការប្រើប្រាស់និងបែងចែងដីក្នុងសហគមន៍តំបន់ការពារធម្មជាតិដូចជា ទេសចរណ៍ ស្រែរួម ដីព្រៃឈើ កសិកម្មសហករណ៍ កសិម្មដំណាំហូបផ្លែ....។
- ✓ ស្នើសុំសិទ្ធិក្នុងការដកហូត អនុផលព្រៃឈើ ដើម្បីធ្វើអាជីវកម្ម នឹងមានការដឹកជញ្ជូនទៅកាន់ទីផ្សារសហគមន៍តំបន់ការពារធម្មជាតិ(សិទ្ធិក្នុងការដឹកជញ្ជូន)។
- ✓ តំបន់សក្តានុពលរៀបចំទេសចរណ៍សហគមន៍ ច្បាប់ថ្មីគួរលើកទឹកចិត្តក្នុងការរៀបចំ សម្រួលទាំងដំណើរការ និងឯកសារ ព្រមទាំងទុនបម្រុងក្នុងការបង្កើតអេកូទេសចរណ៍សហគមន៍ ។
- ✓ ជនណាក៏ដោយឱ្យតែប្រព្រឹត្តិបទល្មើសធនធានធម្មជាតិត្រូវទទួលទោស រួមទាំងអ្នករួមគំនិត ញុះញង់។
- ✓ ស្នើសុំបន្ថែមពាក្យក្នុងច្បាប់តំបន់ការពារធម្មជាតិថ្មីអំពី ការបង្កើតសហគមន៍តំបន់ការពារធម្មជាតិគឺទំហំដែលផ្តល់ជូនជាសហគមន៍តំបន់ការពារធម្មជាតិ ត្រូវមានទំហំសាកសមនិងសមរម្យល្មមសំរាប់សហគមន៍អាចទាញយកអត្ថប្រយោជន៍បានសំរាប់សកម្មភាពបង្កបង្កើនជីវភាពប្រជាពលរដ្ឋ តាមរយៈ ទេសចរណ៍ ពាណិជ្ជកម្មអនុផលព្រៃឈើ ការអភិរក្សព្រៃឈើនិងធនធានកម្រ និងផ្សេងៗ ។
- ✓ ស្នើសុំបន្ថែមដាក់ទោសដល់បុគ្គល ឬសមាជិកគណៈកម្មាធិការរបស់សហគមន៍តំបន់ការពារធម្មជាតិដែលចូលរួមបទល្មើស មិនគោរពលក្ខន្តិកៈ និងផែនការគ្រប់គ្រងសហគមន៍។

## ៤. មតិយោបល់រួមពាក់ព័ន្ធនឹងសេចក្តីព្រាងច្បាប់ទាំង២

- ✓ ស្នើសុំកំណត់តួនាទី និងការទទួលខុសត្រូវរបស់អាជ្ញាធរដែនដី(សម្របសម្រួលនិងត្រួតពិនិត្យ) និងសហគមន៍ក្នុងសេចក្តីព្រាងព្រៃឈើ និងសេចក្តីព្រាងច្បាប់ស្តីពីតំបន់ការពារធម្មជាតិ និងត្រូវមានបទប្បញ្ញត្តិចែងពីការគាំទ្រ(ធនធានហិញ្ញវត្ថុ) អាជ្ញាធរថ្នាក់ក្រោមជាតិក្នុងការគ្រប់គ្រងតំបន់ការពារធម្មជាតិពីរាជរដ្ឋាភិបាល ។
- ✓ បង្កើនថវិកាជាតិ(មូលនិធិឃុំ) ក្នុងការការពារធនធានធម្មជាតិ / ព្រៃសហគមន៍។
- ✓ រាជរដ្ឋាភិបាល អាជ្ញាធរពាក់ព័ន្ធបង្កើនការគាំទ្រលើកម្មវិធីរេដបូក(REDD+)។
- ✓ អាជ្ញាធរមូលដ្ឋានគួរផ្តល់ការគាំទ្រ និងលើកទឹកចិត្តដល់សហគមន៍តំបន់ការពារធម្មជាតិផ្តល់តាមរយៈ ហេដ្ឋារចនាសម្ព័ន្ធល្អ សេវាសាធារណៈល្អ។
- ✓ ធ្វើឱ្យមានសង្គតិភាពនៃច្បាប់ថ្មីដែលផ្តល់វិមជ្ឈការអំណាចគ្រប់គ្រងព្រៃឈើក្នុងតំបន់សហគមន៍តំបន់ការពារធម្មជាតិ និងច្បាប់ស្តីការគ្រប់គ្រងរដ្ឋបាលឃុំ សង្កាត់ ដែលហាមមិនឱ្យក្រុមប្រឹក្សាឃុំ សង្កាត់ប៉ះ

ពាល់ដល់ការងារគ្រប់គ្រងព្រៃឈើ ។ ចំណុចនេះ គួរធ្វើវិសោធនកម្មច្បាប់គ្រប់គ្រងឃុំ សង្កាត់ ដើម្បីបន្សុីគ្នា ។ (ប្រកាសប្រតិភូកម្មមុខងារតំបន់ការពារចំនួន៧២)។

- ✓ អាជ្ញាធរ និងមន្ត្រីជំនាញដែលពាក់ព័ន្ធ ចូលរួមគាំទ្រសហគមន៍ឱ្យមានការសហការក្នុងការទប់ស្កាត់បទល្មើសព្រៃឈើ។
- ✓ ធ្វើការអប់រំដល់ជនល្មើស ហើយក្នុងករណីមិនរៀងចាល ត្រូវបញ្ជូនជនល្មើសទៅតុលាការ។
- ✓ មន្ត្រីឧទ្យានុរក្ស និងអាជ្ញាធរពាក់ព័ន្ធត្រូវសកម្មចូលរួមល្បាតព្រៃឈើជាប្រចាំ ។
- ✓ ផ្សព្វផ្សាយច្បាប់ស្តីពីព្រៃឈើ/ តំបន់ការពារជាប្រចាំ។
- ✓ ភាគលាភពីការផាកពិន័យបទល្មើសត្រូវបែងចែកដល់សហគមន៍។
- ✓ ច្បាប់ថ្មីគួរបង្កើនសិទ្ធិ គាំទ្រ និងលើកទឹកចិត្តដល់សហគមន៍ និងអ្នកពាក់ព័ន្ធក្នុងសកម្មភាព បង្ការនិងទប់ស្កាត់បទល្មើសព្រៃឈើក្នុងតំបន់ការពារធម្មជាតិ។ បង្កើនសិទ្ធិសហគមន៍តាមរយៈការលើកកម្ពស់ជីវភាពស្របតាមលំនឹងធនធានធម្មជាតិ។ បង្ការតាមរយៈសិទ្ធិ ការអប់រំ ផ្សព្វផ្សាយច្បាប់ បណ្តុះសេចក្តីស្រឡាញ់ល្បាត ដាក់បុស្តិ៍ឈាម។ គាំទ្រសហគមន៍តាមរយៈពង្រឹងសមត្ថភាព ជំនាញពាក់ព័ន្ធអភិបាលកិច្ចព្រៃឈើផ្តល់ថវិកាក្នុងការបោះបង្គោលព្រំ ផ្លូវភ្លើង ការដាំដើមឈើឡើងវិញ សកម្មភាពល្បាត។ លើកទឹកសហគមន៍តាមរយៈ ការផ្តល់ប័ណ្ណសរសើរ និងប្រាក់រង្វាន់ដល់សហគមន៍ ឬបុគ្គលគំរូ។ ផ្តល់សិទ្ធិដល់សហគមន៍តំបន់ការពារធម្មជាតិក្នុងការចូលរួមពេញលេញដល់សហគមន៍ក្នុងការចូលរួមបង្ក្រាបបទល្មើសឱ្យមានប្រសិទ្ធភាព។
- ✓ វិសោធន៍កម្មច្បាប់ត្រូវឱ្យមានភាគីពាក់ព័ន្ធមានពេលវេលាគ្រប់គ្រាន់ និងគិតគូរដល់(ជនពិការ ស្រី យុវជន ជនជាតិដើមភាគតិច)។

## ៥. យោបល់បន្ថែមសម្រាប់ការពិចារណាក្នុងការរៀបចំលិខិតបទដ្ឋានគតិយុត្តិក្រោមច្បាប់ពាក់ព័ន្ធ

- ✓ ធ្វើការវាយតម្លៃកម្រិតជីវភាពនិងជីបង្កបង្កើនផលសហគមន៍មុននិងបង្កើតសហគមន៍
- ✓ បន្ថែមរយៈពេលកិច្ចព្រមព្រៀងពី២៥ទៅ៣០ឆ្នាំ និងអាចបន្តបានសាជាថ្មីដោយផ្អែកលើរបាយការណ៍និងការវាយតម្លៃរបស់មន្ត្រីទទួលបន្ទុករបស់ក្រសួងបរិស្ថាន និងអាជ្ញាធរមូលដ្ឋាន។
- ✓ ស្នើសុំផ្តល់កាលបរិច្ឆេទច្បាស់លាស់ក្នុងការឆ្លើយតបក្នុងជំហាននិមួយៗក្នុងការរៀបចំជាសហគមន៍តំបន់ការពារធម្មជាតិ។ កំណត់រយៈពេលនៃការទទួលស្គាល់សហគមន៍តំបន់ការពារធម្មជាតិពីក្រសួងយ៉ាងយូរត្រឹម០២ឆ្នាំ។
- ✓ គួរកំណត់លក្ខខណ្ឌសម្រាប់ការដកហូត/លុប ឬបន្តកិច្ចព្រមព្រៀងរបស់សហគមន៍ឱ្យបានច្បាស់លាស់។ ក្នុងករណីកិច្ចព្រមព្រៀងរបស់សហគមន៍ត្រូវបានដកហូតត្រូវមានការពិគ្រោះយោបល់។
- ✓ សហគមន៍តំបន់ការពារធម្មជាតិទទួលបានសេចក្តីប្រកាសទទួលស្គាល់មិនត្រូវឱ្យភាគីផ្តល់ដីសម្បទានជាន់គ្នាជាមួយសហគមន៍តំបន់ការពារផ្សេងទៀតឡើយ។

- ✓ ស្នើសុំដាក់បញ្ចូលគោលការណ៍FPICនៅក្នុងដំណើរការផ្តល់សម្បទានដីដល់ក្រុមហ៊ុនអភិវឌ្ឍន៍នានា។ ផ្តល់សិទ្ធិសហគមន៍មូលដ្ឋានដែលរង់ប៉ះពាល់ដោយផ្ទាល់ និងអ្នកពាក់ព័ន្ធនៃគម្រោងបានចូលរួមពេញលេញក្នុងដំណើរការពិគ្រោះយោបល់ជាសាធារណៈ ពេលគឺទទួលបានព័ត៌មានពិតប្រាកដ គ្រប់គ្រាន់ យល់ច្បាស់អំពីគម្រោងអភិវឌ្ឍន៍ ផល និងហេតុប៉ះពាល់ ផែនការកាត់បន្ថយនិងដំណោះស្រាយផលប៉ះពាល់ និងផ្តល់សិទ្ធិឱ្យសហគមន៍មូលដ្ឋានបានធ្វើការសម្រេចចិត្តលើគម្រោងអភិវឌ្ឍន៍។
- ✓ ពង្រឹងការអនុវត្តមាត្រា៣៥នៃសេចក្តីណែនាំការបង្កើតសហគមន៍តំបន់ការពារធម្មជាតិ និងមាត្រា២៥នៃច្បាប់ស្តីពីតំបន់ការពារធម្មជាតិ ស្តីពីសិទ្ធក្នុងការលប់ឬដកហូតសហគមន៍តំបន់ការពារធម្មជាតិ ដោយសារសហគមន៍មិនបានអនុវត្តតាមលក្ខន្តិកៈ ឬផែនការគ្រប់គ្រង។ ករណីការដកហូតតាមតម្រូវការបម្រើផលប្រយោជន៍សាធារណៈ សហគមន៍ត្រូវទទួលបាននូវដំណោះស្រាយ ឬសំណងសមរម្យពីគម្រោង។
- ✓ ស្នើសុំបញ្ចូលរចនាសម្ព័ន្ធសហគមន៍ជាផ្លូវការជាមួយស្ថាប័នរដ្ឋ(ដូចឃុំ ស្រុក ខេត្តដែរ) និងមានអាណត្តិបោះឆ្នោត។
- ✓ ផ្តល់សិទ្ធិឱ្យសហគមន៍តំបន់ការពារធម្មជាតិមានសិទ្ធិជាដើមបណ្តឹងរដ្ឋប្បវេណីដើម្បីទាមទារសំណងជួសជុលការខូចខាត(ព្យសនកម្ម)ព្រៃឈើ និងធនធានជីវចម្រុះផ្សេងទៀតរបស់សហគមន៍ បណ្តាលមកពីសកម្មភាពល្មើស។
- ✓ ត្រូវមានមេធាវីការពារសហគមន៍ ត្រូវអនុវត្តច្បាប់ និងដាក់ទោសទណ្ឌឱ្យបានម៉ឺងម៉ាត់ ក្រឹត្យក្រម។
- ✓ បង្កើតប្រព័ន្ធត្រួតពិនិត្យការអនុវត្តច្បាប់ និងអ្នកពាក់ព័ន្ធ (អាជ្ញាធរ ប្រជាពលរដ្ឋ ។ល។ អង្គការសង្គមស៊ីវិល) ចូលរួមតាមដាន និងវាយតម្លៃ។
- ✓ ស្នើសុំការគាំទ្រថវិកាក្នុងការជួយអភិរក្សការពារធនធានធម្មជាតិ (ថវិកា សម្ភារៈសម្រាប់ការកសាងសមត្ថភាព ជួយដល់ជនងាយរងគ្រោះ(កុមារ និងស្ត្រី)។
- ✓ លើកកម្ពស់ការចូលរួមរបស់ស្ត្រី ក្រុមយុវជន ជំនាន់ក្រោយជាទំពាំងស្នងឫស្សី។
- ✓ ផ្តល់សិទ្ធិដល់សហគមន៍ក្នុងការចូលរួមពិគ្រោះយោបល់ និងធ្វើការសម្រេចចិត្ត។
- ✓ ស្នើសុំឱ្យមានវគ្គបណ្តុះបណ្តាល និងគាំទ្រឱ្យការកែច្នៃនិងការរៀបចំតំបន់ធម្មជាតិឱ្យក្លាយជាសហគមន៍អេកូទេសចរណ៍។
- ✓ ស្នើសុំឱ្យមានការកំណត់ទីតាំងលើផែនទីវាងតំបន់ការពារធម្មជាតិ និងដីជនជាតិដើមភាគតិច ដែលជាន់លើផែនទីគ្នា ដែលនាំឱ្យបាត់បង់សិទ្ធិជនជាតិដើមភាគតិច។
- ✓ ចូលរួមបង្កា និងការពារភ្លើងឆេះព្រៃ។
- ✓ ស្នើសុំឱ្យមានវេទិកាសាធារណៈនៅជុំវិញតំបន់គម្រោង។
- ✓ ស្នើសុំឱ្យមានការចូលរួមផ្តល់ព័ត៌មានពីសហគមន៍មូលដ្ឋាន។
- ✓ គួរមានផ្សព្វផ្សាយវគ្គច្បាប់ថ្មីឱ្យបានទូលំទូលាយ បន្ទាប់ពីច្បាប់ថ្មីបានអនុម័ត ។
- ✓ ផ្តល់ការបណ្តុះបណ្តាល និងគាំទ្រឱ្យការកែច្នៃ និងការរៀបចំសហគមន៍អេកូទេសចរណ៍។

- ✓ គួរបន្ថែមរយៈពេលកិច្ចព្រមព្រៀងដល់២៥ឆ្នាំតែម្តង ត្រូវមានការត្រួតពិនិត្យការអនុវត្តសហគមន៍រាល់៣ឆ្នាំម្តង ។
- ✓ មន្រ្តីបរិស្ថាន និងរដ្ឋបាលព្រៃឈើ ឬអង្គភាពជំនាញទទួលបន្ទុកព្រៃឈើត្រូវចាត់វិធានការលើបទល្មើសព្រៃឈើនោះឱ្យទាន់ពេលវេលា។
- ✓ រាជរដ្ឋាភិបាលមិនត្រូវអនុញ្ញាតឱ្យធ្វើការអភិវឌ្ឍនានាពីវិស័យឯកជន។
- ✓ អនុផលព្រៃឈើដែលរើបអូសគួរផ្តល់ជូនសហគមន៍។
- ✓ លើកទឹកចិត្តដល់សហគមន៍ដែលមានស្នាដៃ ក្នុងការអភិរក្ស និងការពារបានល្អ។
- ✓ រាជរដ្ឋាភិបាលលើកទឹកចិត្តដល់ប្រជាពលរដ្ឋក្នុងការចូលរួមការពារធនធានធម្មជាតិ។
- ✓ ពន្លឿន ឬកំណត់តំបន់ស្នូល និងតំបន់ការពារ ប្រើប្រាស់ដោយចីរភាព។
- ✓ កំណត់តួនាទី និងការទទួលខុសត្រូវរបស់អាជ្ញាធរដែនដី( សម្របសម្រួលនិងត្រួតពិនិត្យ ) និងសហគមន៍ក្នុងសេចក្តីព្រាងព្រៃឈើ និងសេចក្តីព្រាងច្បាប់ស្តីពីតំបន់ការពារធម្មជាតិ និងត្រូវមានបទប្បញ្ញត្តិចែងពីការគាំទ្រ( ធនធានហិញ្ញវត្ថុ )អាជ្ញាធរថ្នាក់ក្រោមជាតិក្នុងការគ្រប់គ្រងតំបន់ការពារធម្មជាតិពីរដ្ឋបាភិបាល ។

## ៦. សេចក្តីសន្និដ្ឋាន

ផ្អែកតាមការពិភាក្សា ពិគ្រោះយោបល់ និងការផ្តល់មតិយោបល់នានារបស់អង្គសិក្ខាសាលា អ្នកសម្របសម្រួលអាចសន្និដ្ឋានជារួមបានថា ធាតុចូលដែលប្រមូលបានពីសិក្ខាសាលាទាំងបីតំបន់ គឺពិតជាមានសារសំខាន់ និងអាចយកមកពិចារណាក្នុងការដាក់បញ្ចូលនៅក្នុងសេចក្តីព្រាងវិសោធន៍កម្មច្បាប់ស្តីពីតំបន់ការពារធម្មជាតិ និងច្បាប់ស្តីពីព្រៃឈើ ដែលពាក់ព័ន្ធនឹងជំពូកដែលបរិយាយអំពីការចូលរួមនិងសិទ្ធិរបស់សហគមន៍។

**ថ្ងៃ.................. ខែ.......... ឆ្នាំខាល ចត្វាស័ក ព.ស២៥៦៦**

**រាជធានីភ្នំពេញ ថ្ងៃទី........... ខែ....... ឆ្នាំ២០២២**

**អ្នករៀបចំរបាយការណ៍**